# អាជ្ញាធរខេត្តនិងមន្ត្រីសិទ្ធិមនុស្សប៉ះពាក្យសម្ដីគ្នាក្នុងវេទិកាសាធារណៈ

ដោយ អ៊ួន ឈិន

2011-05-31

មានការប៉ះទង្គិចពាក្យសម្ដីគ្នារវាងមន្ត្រីអាជ្ញាធរខេត្ត ព្រះវិហារ និងមន្ត្រីរៀបចំវេទិកាសាធារណៈនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

ការប៉ះទង្គិចពាក្យសម្ដីបានកើតឡើងនៅចុងបញ្ចប់នៃវេទិកាសាធារណៈ ស្ដីពីសិទ្ធិមនុស្ស និងការអភិវឌ្ឍដែលរៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងដោយមានកិច្ចសហការពីសំណាក់អង្គការការពារធនធានធម្មជាតិ នៅភូមិប៉ាលហាល ឃុំរីករាយ ស្រុករវាង ខេត្តព្រះវិហារ ខណៈដែលមន្ត្រីសម្របសម្រួលវេទិកាស្នើសុំឲ្យអភិបាលរងខេត្តព្រះវិហារ លោកស្រី ខូយ ប៊ុនថាន បូកសរុបខ្លឹមសារនៃការជជែកពិភាក្សាឲ្យចំនឹងសំណួររបស់ប្រជាពលរដ្ឋ ដែលធ្វើឲ្យលោកស្រីមានប្រតិកម្មដោយចោទប្រកាន់ថា មន្ត្រីសម្របសម្រួលបើកឱកាសឲ្យតំណាងរាស្ត្រគណបក្សដទៃនិយាយច្រើនជាង រូបគាត់។

មន្ត្រីសម្របសម្រួលគម្រោងពង្រឹងអំណាចសហគមន៍នៃមជ្ឈមណ្ឌល សិទ្ធិមនុស្សកម្ពុជា លោក ឈឹម សារុធ មានប្រសាសន៍ពន្យល់ថា វេទិកាបានផ្ដល់ឱកាសស្មើៗគ្នាដល់គ្រប់វាគ្មិនដែលបានចូលរួម។

វេទិកាសាធារណៈនៅស្រុករវៀង បានបើកឲ្យមានការជជែកពិភាក្សារវាងប្រជាពលរដ្ឋនៃសហគមន៍ព្រៃឡង់ ជាមួយអ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយមួយចំនួន មន្ត្រីអាជ្ញាធរ និងមន្ត្រីនៃស្ថាប័នដែលពាក់ព័ន្ធ ស្ដីពីការប៉ះពាល់ដោយសារការផ្ដល់ដីសម្បទានសេដ្ឋកិច្ចទៅឲ្យ ក្រុមហ៊ុនធ្វើការអភិវឌ្ឍជាចម្ការកៅស៊ូនៅតំបន់ព្រៃឡង់។

ប្រជាពលរដ្ឋបានលើកនូវសំណួរជាច្រើនទៅកាន់វាគ្មិន។ ក្នុងការឆ្លើយតបទៅនឹងសំណួររបស់ប្រជាពលរដ្ឋ តំណាងរាស្ត្រមកពីគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានលើកយកភាពចន្លោះប្រហោងក្នុងការការពារ ធនធានធម្មជាតិដើម្បីធ្វើការប្រហារទៅលើរដ្ឋាភិបាល ហើយលោកស្រី ខូយ ប៊ុនថាន ដែលជាមន្ត្រីមកពីគណបក្សប្រជាជនក៏បានធ្វើការវាយបកតបវិញដែរ។

លោក ឈឹម សារុធ ថ្លែងបន្តថា ចម្លើយរបស់មន្ត្រីអាជ្ញាធរ និងមន្ត្រីនៃស្ថាប័នដែលពាក់ព័ន្ធ ភាគច្រើនមិនតបទៅនឹងសំណួររបស់ប្រជាពលរដ្ឋនោះទេ។

ទោះយ៉ាងណា លោក ឈឹម សារុធ អះអាងថា វេទិកានេះទទួលបានជោគជ័យដោយមានប្រជាពលរដ្ឋចូលរួមប្រមាណ ៦០០នាក់ លើសពីការរំពឹងទុកដែលលោកត្រៀមកៅអីសម្រាប់មនុស្សតែ ៣០០នាក់ប៉ុណ្ណោះ ហើយប្រជាពលរដ្ឋបានលើកជាសំនួរល្អៗដែលបញ្ជាក់ពួកគាត់មានការ យល់ដឹងខ្ពស់អំពីការការពារបរិស្ថាននិងធនធានធម្មជាតិ៕